**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ២៨៩៤/២៤ កសក.អ៩

ថ្ងៃ អង្គារ ១០កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

**ជម្រាបមក**

**លោកប្រធានក្រុមហ៊ុន ខេ ខេ អេស ១៥៣ ឯ.ក**

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យា ស្តីពីការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកប្រធាន** ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោក ដើម្បីធ្វើការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ប្រចាំឆ្នាំ២០២៤ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន **៨៨១ ៣៨០ ០០០៛ (ប្រាំបីរយប៉ែតសិបមួយលានបីរយប៉ែតសិបពាន់រៀលគត់)** ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** ជ្រាបជាព័ត៌មានតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

**គីម សុន**

**ចម្លងជូន៖**

-នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

-ក្រុមហ៊ុន វី អាយ អេស អេស(ខេមបូឌា) ឯ.ក

-ក្រុមហ៊ុន សលីដ រ៉ក់

"ដើម្បីជ្រាប"

-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax: (855) 23-217 320